អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jan-2012, 09:27
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(១៣)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(13)

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Motoo NOGUCHI**
**ចៅក្រម សោម សិរិវឌ្ឍ**
**ចៅក្រម Agnieszka KLONOWIECKA-MILART**
**ចៅក្រម ម៉ុង មុនីចរិយា**
**ចៅក្រម Chandra Nihal Jayasinghe**
**ចៅក្រម យ៉ា ណារិន**

| | |
|---|---|
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ |
| ភាសា | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

---

# សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យឋិតជាប់ចោទមានវត្តមានក្នុងសាលសវនាការ

---

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥) -២៣-២១៩-៨១៤ ទូរសារ: (៨៥៥) -២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, Phnom Penh, P.O. Box 71, Phnom Penh Tel:+855(0)23 219814 Fax:023 219841 Web: www.eccc.gov.kh

**<u>មេធាវីការពារក្តីជនជាប់ចោទ អៀង សារី</u>**

អាង ឧត្តម

Michael G.KARNAVAS

**<u>ជនជាប់ចោទ</u>**

អៀង សារី

**<u>សហព្រះរាជអាជ្ញា</u>**

លោកស្រី ជា លាង

លោក Andrew CAYLEY

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Elisabeth SIMMONEAU-FORT

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”)៖

**ទទួលបាន**បណ្តឹងសាទុក្ខភ្លាមៗដែលដាក់ដោយសហមេធាវីការពារក្តីជនជាប់ចោទ អៀង សារី (“សហមេធាវីការពារក្តី”) (“បណ្តឹងសាទុក្ខ”)[1]។

**ពិចារណាលើ**ទឡ្ហីករណ៍នៅក្នុងបណ្តឹងសាទុក្ខដែលបានលើកឡើងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[2] ដែលតម្រូវឱ្យជនជាប់ចោទមានវត្តមាននៅក្នុងសាលសវនាការអំឡុងពេលបើកកិច្ចពិភាក្សាដេញដោល ទោះបីជាជនជាប់ចោទមានការឈឺចាប់ និងភាពលំបាកផ្នែករាងកាយក៏ដោយ បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការជួយដល់មេធាវីក្នុងការការពារខ្លួនគាត់ និងមិនបានទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទក្នុងការបដិសេធមិនចូលរួមក្នុងសវនាការ ព្រមទាំងជាការដាក់ទណ្ឌកម្មមួយដែលមិនមានចែងនៅក្នុងច្បាប់ ដែលទាំងនេះជាការជ្រៀតជ្រែកដោយដឹង និងមានចេតនា ទៅលើកិច្ចការរដ្ឋបាលតុលាការ ដោយយោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨)។

**ដោយពិចារណាឃើញ**ថា គ្មានកំហុសអង្គច្បាប់ ឬ អង្គហេតុ និងគ្មានការរំលោភនូវឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងណាមួយ ដែលអាចបង្កើតបានជាការជ្រៀតជ្រែកដោយដឹង និងមានចេតនា ទៅលើកិច្ចការរដ្ឋបាលតុលាការ ដោយយោងតាមអត្ថន័យនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ។

**ដោយពិចារណាឃើញ**ថា ខ្លឹមសារនៃបណ្តឹងសាទុក្ខមិនស្ថិតនៅក្នុងយុត្តាធិការដែលមានកម្រិតរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើបណ្តឹងសាទុក្ខភ្លាមៗ យោងតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុងនោះទេ[3]។

---

[1] បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានបដិសេធសិទ្ធិសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសាលសវនាការក្នុងអំឡុងពេលជំនុំជម្រះក្តី និងបដិសេធសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញក្នុងការទទួលបានការជួយការពារក្តីដោយខ្លួនគាត់ សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ/អ.ជ.ត.ក(១៣) ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E130/4/1។

[2] ប្រតិចារឹក(ភាសាអង់គ្លេស) ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E1/13.1 ទំព័រ ៣៦។ ប្រតិចារឹក(ភាសាអង់គ្លេស) ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E1/14.1 ទំព័រ ៨។

[3] សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម ២ និង ៣) ប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៩, ឯកសារលេខ E169/1/2, កថាខណ្ឌ ៨-១២។

**ហេតុដូច្នេះ**

**យោងតាមសំអាងហេតុខាងលើ** អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖

**បដិសេធ**បណ្តឹងសាទុក្ខនេះ។

**រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២**
**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**